www.kidworship.kr

# ប៉ម បាបិល

- 5th Story -



29Page

**Nar** ចាប់តាំងពីថ្ងៃដែលទូកធំណូអេនិងទឹកជំនន់បានផុតជាច្រើនថ្ងៃហើយ។
ពេលនោះ  ណូអេ មានកូនចៅច្រើនណាស់ ដែលពួកគេទាំងអស់គ្នានិយាយភាសាតែមួយ។  នៅពេលដែលកូនចៅរបស់ណូអេបានផ្លាស់ទៅរស់នៅទិសខាងកើត ពួកគេបានឃើញទីកន្លែងមួយហើយក៏ស្នាក់នៅទីនោះ។

**Man with raised hand** អូ! មីងសំ! តើមីងលក់ផ្លែឈើដាច់ដែរទេ?

**Woman with yellow hat** អូ! ពូផាក! លក់អត់ដាច់ទេ! មើលនែ!
ហាហាហា (សំលេងដែលចេញពីហ្វូងមនុស្ស។

**Nar** ពេលនោះ  ចំនួនមនុស្សកាន់តែច្រើនឡើង ឯភូមិក៏កាន់តែធំដែរ។ ពួកគេបានសង់ផ្ទះដ៏រឹងមាំពីឥដ្ឋ ហើយមានអាហារបរិភោគគ្រប់គ្រាន់។

**Man with purple clothes** តោះយើងសាកសង់អគារធំមួយដោយប្រើឥដ្ឋទាំងអស់នេះមើល?

**Nar** នៅពេលដែលមនុស្សកាន់តែមានប្រាជ្ញា
ពេលនោះចិត្តរបស់ពួកគេក៏ចាប់ផ្ដើមព្រងើយកន្តើយនឹងព្រះ។
មិនយូរប៉ុន្មាន  ពួកមនុស្សទាំងនោះបានគិតថា
ពួកគេអាចធ្វើការអស្ចារ្យដូចជាព្រះដែរ។

---



30Page

**Man with raised hand** តោះយើងនាំគ្នាសង់ប៉ម  ដែលខ្ពស់ជាងគេបំផុតនៅលើពិភពលោក។ បើយើងមានប៉មនេះហើយ នោះគ្មានអ្នកណាអាចធ្វើបាបយើងបានទេ ហើយយើងក៏អាចអស្ចារ្យដូចជាព្រះដែរ។

**Woman in pink** សូម្បីតែព្រះជាម្ចាស់
ក៏មិនអាចដាក់ទោសដល់ពួកយើងបានដោយងាយដែរ។

**Nar** មនុស្សទាំងអស់ មានភាពលោភលន់កាន់តែខ្លាំងឡើងៗ
ហើយក៏ចាប់ផ្ដើមសាងសង់ប៉មដ៏ខ្ពស់នោះ។
ពួកគេក៏ចាប់ផ្ដើមសាងសង់ប៉មមួយ ដែលអាចទៅដល់ឋានសួគ៌។



31Page

**People** ខ្ពស់ទៀត! ខ្ពស់តិចទៀត!  មកដល់ឋានសួគ៌ហើយ យេ! យេ!
នេះហើយជាឋានសួគ៌! ទីបំផុត យើងមកដល់ឋានសួគ៌ហើយ!
អូហ្វ!  ពិតជាស្អាតណាស់!

**Nar** មនុស្សទាំងអស់ មិនបានសួរពីព្រះទ័យព្រះជាម្ចាស់ទេថា
ទ្រង់ពេញចិត្តឲ្យសង់ប៉មនោះរឺក៏អត់។  ពួកគេបានអួតខ្លួន
ហើយលែងកោតខ្លាចដល់ព្រះជាម្ចាស់ថែមទៀតផង។

ជារៀងរាល់ថ្ងៃ  ប៉មនោះកាន់តែខ្ពស់ទៅៗ។
ព្រះជាម្ចាស់ទតឃើញប៉ម  ដែលមនុស្សកំពុងតែសង់
ពេលនោះ ព្រះអង្គមិនសប្បាយចិត្តទេ។
ដូច្នេះហើយ  ព្រះបានប្តូរភាសារបស់ពួកគេទៅជាភាសាផ្សេងៗ
ដើម្បីកុំអោយពួកគេស្តាប់គ្នាយល់ទៀត។


32Page

**Man 1** សូមអោយញញួរមកខ្ញុំ!
**Man 2** តើឯងនិយាយអ្វី?
**Man 3** រ៉ូកា, រ៉ូកា, យូកូ??
**Man 4** ហូឡូឡូ  កូឡូឡូ។
**Man 5** តើទាំងនេះសំលេងជាអ្វី? តើមានអ្វីកើតឡើងហ្នឹង?
**Man 6** ប៉ូហា!ប៉ូហា!  ណានី? ណានី?


33Page

**Nar** ពេលនេះ  មនុស្សទាំងអស់ មិនអាចស្តាប់ភាសាគ្នាយល់បានទេ។
ការយល់ច្រឡំរបស់ពួកគេ  ក៏កាន់តែខ្លាំងឡើងៗ
ហើយពួកគេក៏ចាប់ផ្តើមខឹងគ្នា។
មនុស្សទាំងអស់ មិនអាចធ្វើការជាមួយគ្នាបានទៀតទេ។
ពួកគេក៏ឈប់សាងសង់ប៉មនោះ
ហើយពួកគេត្រូវខ្ចាត់ខ្ចាយទៅរស់នៅពាសពេញផែនដី។
បន្ទាប់មកទៀត  មនុស្សទាំងអស់ក៏ទទួលស្គាល់ ថាព្រះជាម្ចាស់
ពិតជាមានអំណាចអស្ចារ្យមែន។
ប៉មនោះត្រូវបានគេហៅថា  ˝ប៉ម បាបិល˝។
ក្រោយមក  ពួកគេមិនអាចសង់បង្ហើយប៉មនោះបានទៀតទេ។